# ព្រះរាជក្រឹត្យ នស.រកត.០២០១.០៣១

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០០

## ត្រាស់បង្គាប់

**មាត្រា ១ ៈ**

ត្រូវបានបង្កើតសញ្ញាសក្តិ និងឯកសណ្ឋានសំរាប់សំគាល់សមាជិករាជរដ្ឋាភិបាល និងអនុរដ្ឋលេខាធិការ ។

**មាត្រា ២ ៈ**

សញ្ញាសក្តិ និងឯកសណ្ឋាននេះ ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ ។

## ជំពូកទី ២

## សញ្ញាជាតិ

**មាត្រា ៣ ៈ**

សញ្ញាសក្តិសមាជិករាជរដ្ឋាភិបាល និងអនុរដ្ឋលេខាធិការ ត្រូវបានកំណត់ដូចតទៅ :

**១.សំរាប់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និង ទេសរដ្ឋមន្ត្រី**

**ក-សត្តិស្ថា** : មានផ្ទៃកម្ពីពណ៌ខៀវ រចនាគុបតែងដោយក្បាច់អង្គរពណ៌មាស មានផ្កាឈូកមួយទង មានបីត្របកនៅកណ្តាល នៅចំពីលើផ្កាឈូកមានសញ្ញារាជរដ្ឋាភិបាល និង នៅលើសញ្ញារាជរដ្ឋាភិបាល មានឡេវរូបព្រះសង្ហារពណ៌មាសមូល ។ មានជរជាយសន្ទឹកក្បាច់អង្គរពណ៌មាសព័ទ្ធជុំវិញ ។ នៅចន្លោះក្បាច់អង្គរ និងក្បាច់ជរជាយមានខ្សែពួរវេញពណ៌មាសបីឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិនាយករដ្ឋមន្ត្រី ពីរឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិឧបនាយករដ្ឋមន្ត្រី មួយឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិទេសរដ្ឋមន្ត្រី និងមានខ្សែពួរវេញពណ៌មាសមួយទៀតព័ទ្ធជុំវិញពីខាងក្រៅ ។

ខ្នាតសក្តិស្ថា ត្រូវបានកំណត់ដូចខាងក្រោមនេះ :-

- បាតក្រោមប្រវែង ៦ សង់ទីម៉ែត្រ
- ទទឹងមុខកាត់ផ្ទៃកខាងលើ ប្រវែង ៤.៤០ សង់ទីម៉ែត្រ មានរាងកោងជាមុំទាល
- បណ្តោយពីលើដល់បាតក្រោមប្រវែង ១៣ សង់ទីម៉ែត្រ

**ខ-សក្តិចុងកអាវ** : មានផ្ទៃកម្ពីពណ៌ខៀវ រចនាគុបតែងដោយក្បាច់អង្គរពណ៌មាស និងមានសញ្ញារាជរដ្ឋាភិបាលពណ៌មាសនៅខាងដើម ។ មានជរជាយសន្ទឹកក្បាច់អង្គរពណ៌មាសនៅផ្ទៃកខាងលើ និងចំហៀងខាងមុខ ។ នៅចន្លោះក្បាច់អង្គរ និងក្បាច់ជរជាយមានខ្សែពួរវេញពណ៌មាសបីឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិនាយករដ្ឋមន្ត្រី ពីរឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិឧបនាយករដ្ឋមន្ត្រី មួយឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិទេសរដ្ឋមន្ត្រី នៅផ្ទៃកខាងលើ និងចំហៀងខាងមុខ ហើយនិងមានខ្សែពួរវេញពណ៌មាសមួយទៀតព័ទ្ធជុំវិញពីខាងក្រៅ ។

ខ្នាតសក្តិចុងកអាវ ត្រូវបានកំណត់ដូចខាងក្រោម :-

- មានរាងជាប្រឡេឡូក្រាម
- បណ្តោយប្រវែង ១១ សង់ទីម៉ែត្រ
- ទទឹងប្រវែង ៤ សង់ទីម៉ែត្រ

**គ-សក្តិចុងដៃអាវនាំងសងខាង** : មានផ្ទៃកម្ពីពណ៌ខៀវ រចនាគុបតែងដោយក្បាច់អង្គរពណ៌មាស និងមានជរជាយសន្ទឹកក្បាច់អង្គរពណ៌មាស នៅជាយផ្ទៃកខាងលើ និងសងខាង ។ នៅចន្លោះក្បាច់អង្គរ និងក្បាច់ជរជាយមានខ្សែពួរវេញពណ៌មាសបីឆ្នូត សំរាប់សំគាល់ឋានន្តរសក្តិនាយករដ្ឋមន្ត្រី ពីរឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិឧបនាយករដ្ឋមន្ត្រី មួយឆ្នូតសំរាប់សំគាល់ ឋានន្តរសក្តិទេស

រដ្ឋមន្ត្រី នៅផ្នែកខាងលើនិងសងខាង ហើយ និងមានខ្សែពួរវេញពណ៌មាស មួយទៀតព័ទ្ធជុំវិញពីខាងក្រៅ ។

ខ្ចាតសក្តិចុងដៃអាវ ទាំងសងខាង ត្រូវបានកំណត់ដូចខាងក្រោមនេះ :-

- មានបួនជ្រុងទ្រវែង
- បណ្តោយប្រវែង ៣២ សង្ទីម៉ែត្រ ចំពោះបុរស និង ២៥ ទៅ ២៨ សង្ទីម៉ែត្រចំពោះនារី អាស្រ័យលើមាឌ
- ទទឹងប្រវែង ១១ សង្ទីម៉ែត្រ

រូបគំនូរសក្តិស្មា សក្តិចុងកអាវ សក្តិចុងដៃអាវ សំរាប់នាយករដ្ឋមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី១ សំរាប់ឧបនាយករដ្ឋមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី២ និងសំរាប់ទេសរដ្ឋមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យនេះ ។

**២-សំរាប់រដ្ឋមន្ត្រី រដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការ**

**ក-សក្តិស្មា :** មានផ្ទៃកម្ទីពណ៌ខ្មៅ រចនាតុបតែងដោយក្បាច់ ភ្ញីទេសពណ៌មាស មានសញ្ញារាជរដ្ឋាភិបាល នៅផ្នែកខាងលើ និងនៅខាងលើសញ្ញារាជរដ្ឋាភិបាល មានឡេវរូបព្រះសង្ហារពណ៌មាសមួយ ។ មានជរជាយសន្លឹកក្បាច់ភ្ញីទេសព័ទ្ធជុំវិញ ។ នៅចន្លោះក្បាច់ភ្ញីទេស និងក្បាច់ជរជាយ មានខ្សែពួរវេញពណ៌មាសបីឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិរដ្ឋមន្ត្រី ពីរឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិ រដ្ឋលេខាធិការ មួយឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអនុរដ្ឋលេខាធិការ ព័ទ្ធជុំវិញពីខាងក្រៅ និងមានខ្សែពួរវេញពណ៌មាសមួយទៀតព័ទ្ធជុំវិញពីខាងក្នុង ។

ខ្ចាតសក្តិស្មា ត្រូវបានកំណត់ដូចខាងក្រោមនេះ :-

- បាតក្រោមប្រវែង ៦ សង្ទីម៉ែត្រ
- ទទឹងមុខកាត់ផ្នែកខាងលើ ប្រវែង ៤.៤០ សង្ទីម៉ែត្រ មានរាងកោងជាមុំទាល
- បណ្តោយពីលើដល់បាតក្រោមប្រវែង ១៣ សង្ទីម៉ែត្រ

**ខ-សក្តិចុងកអាវ :** មានផ្ទៃកម្ទីពណ៌ខ្មៅ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាស និងមានសញ្ញារាជរដ្ឋាភិបាលនៅខាងក្នុង ។ មានជរជាយសន្លឹកក្បាច់ភ្ញីទេសពណ៌មាស នៅផ្នែកខាងលើ និងចំហៀងខាងមុខ ។ នៅចន្លោះក្បាច់ភ្ញីទេស និងក្បាច់ជរជាយ មានខ្សែពួរវេញពណ៌មាស

ត្រសំរាប់សំគាល់ឋានន្តរសក្តិរដ្ឋមន្ត្រី ពីរឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិរដ្ឋលេខាធិការ មួយឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអនុរដ្ឋលេខាធិការ នៅខាងក្រៅផ្នែកខាងលើ និងចំហៀងខាងមុខ ហើយនិងមានខ្សែព្រួរវេញពណ៌មាសមួយទៀតព័ទ្ធជុំវិញពីខាងក្នុង ។

ខ្នាតសក្តិចុងកអាវ ត្រូវបានកំណត់ដូចខាងក្រោមនេះ :-

- មានរាងជាប្រឡេឡូក្រាម
- បណ្តោយប្រវែង ១១ សង្ទីម៉ែត្រ
- ទទឹងប្រវែង ៤ សង្ទីម៉ែត្រ

**គ. សក្តិចុងដៃអាវទាំងសងខាង** : មានផ្ទៃកម្ទីពណ៌ខ្មៅ [illegible] ក្បាច់ភ្ញីទេសពណ៌មាស និងមានជរជាយសន្ទឹកក្បាច់ភ្ញីទេសពណ៌មាសនៅជាយផ្នែកខាងលើ និងសងខាង ។ នៅចន្លោះក្បាច់ភ្ញីទេស និងក្បាច់ជរជាយ មានខ្សែព្រួរវេញពណ៌មាសបីឆ្នូត សំរាប់សំគាល់ឋានន្តរសក្តិរដ្ឋមន្ត្រី ពីរឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិរដ្ឋលេខាធិការ មួយឆ្នូតសំរាប់សំគាល់ ឋានន្តរសក្តិអនុរដ្ឋលេខាធិការ នៅខាងក្រៅ និងមានខ្សែព្រួរវេញពណ៌មាស មួយទៀតព័ទ្ធជុំវិញពីខាងក្នុង ។

ខ្នាតសក្តិចុងដៃអាវ ទាំងសងខាង ត្រូវបានកំណត់ដូចខាងក្រោមនេះ :-

- មានរាងបួនជ្រុងទ្រវែង
- បណ្តោយប្រវែង ៣២ សង្ទីម៉ែត្រ ចំពោះបុរស និង ២៥ ទៅ ២៨ សង្ទីម៉ែត្រចំពោះនារី អាស្រ័យលើមាឌ
- ទទឹងប្រវែង ១១ សង្ទីម៉ែត្រ

រូបគំនូរសក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវ សំរាបរដ្ឋមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធ ទី៤ សំរាបរដ្ឋលេខាធិការ មានដូចក្នុងឧបសម្ព័ន្ធទី៥ និងសំរាប់អនុរដ្ឋលេខាធិការ មានដូចក្នុងឧបសម្ព័ន្ធ ទី៦ នៃព្រះរាជក្រឹត្យនេះ ។

ដោយឡែកសក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវទាំងសងខាងរបស់នារី មានទំហំតូចដូចខាងក្រោមនេះ :-

- ចំពោះសក្តិស្មា អាចមានទំហំ ៨០% ៨៥% ៩០% នៃទំហំសក្តិស្មារបស់បុរស អាស្រ័យលើមាឌរបស់នារី

– សក្តិចុងដៃអាវ អាចមានទំហំទទឹងស្មើនឹង ៧០% ទៅ ៧៥% នៃទំហំទទឹងសក្តិចុងដៃអាវរបស់បុរស អាស្រ័យលើមាឌរបស់នារី

– សក្តិកអាវ មានទំហំទទឹង ៣សង្ទីម៉ែត្រ ទៅ ៣.៥ សង្ទីម៉ែត្រ អាស្រ័យលើមាឌរបស់នារី

## ជំពូកទី ៣

## ប្រភេទឯកសណ្ឋាន និងការប្រើប្រាស់

**មាត្រា ៤ .-**

ប្រភេទឯកសណ្ឋានសំរាប់សមាជិករាជរដ្ឋាភិបាល និងអនុរដ្ឋលេខាធិការ ត្រូវបានកំណត់ដូចខាងក្រោម :

**១-ឯកសណ្ឋានផ្លូវការ**

**ក-ចំពោះបុរស :**

-អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំ គ្មានផែកខ្នង ចុងកអាវទាំងសងខាងមានសក្តិតាមឋានន្តរសក្តិ មានបន្ទះលើស្មាសំរាប់ដាក់សក្តិ មានហោប៉ៅចោះ មានគំរោងរាងស្លឹកពោធិខាងលើពីរ ខាងក្រោមពីរ ។ អាវដៃវែង ចុងដៃអាវមានសក្តិ តាមឋានន្តរសក្តិ អាវបិទឡេវមុខ ដោយដាក់ឡេវរូបព្រះរាជសង្ហារចំនួនប្រាំពីរ ។

-ខោជើងវែងពណ៌ស ស្បែកជើងឃ្មុបពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

**ខ-ចំពោះនារី :**

-អាវជីបរាងពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវរបស់បុរស កតាំង គ្មានផែកខ្នង បិទឡេវមុខ ដាក់ឡេវរូបព្រះរាជសង្ហារចំនួនប្រាំ និងមានរាងមូលនៅជាយអាវខាងក្រោម ។ ចុងកអាវទាំងសងខាងមានសក្តិ តាមឋានន្តរសក្តិ មានបន្ទះលើស្មាសំរាប់ដាក់សក្តិ គ្មានហោប៉ៅ អាវដៃវែងត្រឹមភ្នែកគោលដៃ ចុងដៃអាវមានសក្តិ តាមឋានន្តរសក្តិ ។

ឯកសណ្ឋានផ្លូវការ មាន ៣ប្រភេទ :-

-ប្រើសំពត់សំឡុយអំពីជាមួងពណ៌តាមថ្ងៃ ចាក់ជើងអំពីសូត្រ ពណ៌ខ្ចីជាងពណ៌សំពត់ ហៅថាឯកសណ្ឋានផ្លូវការ ប្រភេទលេខ១ ។

-ប្រើសំពត់សំឡុយអំពីជាមួងពណ៌តាមថ្ងៃ ចាក់ជើងសែសយពណ៌ប្លាទីនមាស តាមក្បាច់ជរជើងឯកភាពគ្នា ហៅថាឯកសណ្ឋានផ្លូវការ ប្រភេទលេខ២ ។

-ប្រើសំពត់សំឡុយអំពីហូល តាមគោមឯកភាពគ្នា ហៅថាឯកសណ្ឋានផ្លូវការ ប្រភេទលេខ៣ ។

-ស្បែកជើងអេស្កាប៉ាងឃ្មុបមុខ និងជិតកែងពណ៌ស កាបូបយួរដៃពណ៌ស សំរាប់ពេលព្រឹក ដល់ថ្ងៃត្រង់ ។

-ស្បែកជើងអេស្កាប៉ាងឃ្មុបមុខ និងជិតកែងពណ៌ខ្មៅ កាបូបយួរដៃពណ៌ខ្មៅ សំរាប់ពេលល្ងាច ។

-គំនូរឯកសណ្ឋានសំរាប់សមាជិក សមាជិកា រាជរដ្ឋាភិបាល ទេសាភិបាល ទេសាភិបាលរង និងអនុរដ្ឋលេខាធិការ ទាំងបុរស ទាំងនារី មានដូចក្នុងឧបសម្ព័ន្ធទី ៧ នៃព្រះរាជក្រឹត្យនេះ ។

**២-ឯកសណ្ឋានប្រពៃណីជាតិ**

**ក-ចំពោះបុរស :**

-អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំ គ្មានផែកខ្នង ចុងកអាវទាំងសងខាងមានសក្តិតាមឋានន្តរសក្តិ មានបន្ទះលើស្មាសំរាប់ដាក់សក្តិ មានហោប៉ៅចោះ មានគំរបរាងស្លឹកពោធិខាងលើពីរ ខាងក្រោមពីរ ។ អាវដៃវែង ចុងដៃអាវមានសក្តិ តាមឋានន្តរសក្តិ អាវបិទឡេវមុខ ដោយដាក់ឡេវរូបព្រះរាជសង្ហារចំនួនប្រាំពីរ ។

-សំពត់ផាមួងចងក្បិនពណ៌តាមថ្ងៃ ស្បែកជើងឃ្មុបពណ៌ខ្មៅចងខ្សែ ស្រោមជើងពណ៌ខ្មៅ ដល់ជង្គង់ ។

**ខ-ចំពោះនារី :**

-អាវជីបរាងអំពីសូត្រពណ៌ស ដៃវែងត្រឹមភ្នែកគោលដៃ កវៀលមូលខាងមុខធ្លាក់ចុះពីក្បាលឆ្អឹងដងកាំបិត ១.៥ សង្ទីម៉ែត្រ និងត្រង់ស្មា ឃ្លាតពីគល់កប្រមាណ ២.៥ សង្ទីម៉ែត្រទៅ ៣.០០ សង្ទីម៉ែត្រ អាស្រ័យទៅតាមមាឌរបស់នារី គ្មានសក្តិស្មា និងសក្តិចុងកអាវ ប៉ុន្តែមានសក្តិចុងដៃអាវទាំងសងខាង តាមឋានន្តរសក្តិ ។

-ពានាក្រមាអំពីសូត្រ ដែលមានផ្ទៃពណ៌ខ្ចីជាងសំពត់ ចាក់ជាយតាមបណ្តោយក្រមា និងចុងជាយទទឹងក្រមាអំពីសូត្រ ពណ៌ចាស់ដូចសំពត់ តាមក្បាច់ឯកភាពគ្នា ឬ ក្រមាសូត្រពណ៌ស៊ីន្ទូន តាមការកំណត់របស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ ដោយប្រើ

កន្ទាស់សំរាប់ខ្ចាស់ ក្រមាពានាជាកន្ទាស់អំពីសញ្ញារាជរដ្ឋាភិបាល ដែលមានទំហំទទឹង ៥ សង្ទីម៉ែត្រ និងកំពស់ ៧ សង្ទីម៉ែត្រ ។

-ឯកសណ្ឋានប្រពៃណី មាន ៣ប្រភេទ :-

-ឯកសណ្ឋានប្រពៃណី ដែលប្រើសំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ និងពានាក្រមា ហៅថាឯកសណ្ឋានប្រពៃណី ប្រភេទលេខ១ ។

-ឯកសណ្ឋានប្រពៃណី ដែលប្រើសំពត់ហូលតាមគោមឯកភាពគ្នានិងពានាក្រមាពណ៌ស៊ីនួន ហៅថាឯកសណ្ឋានប្រពៃណី ប្រភេទលេខ២ ។

-ស្បែកជើងពណ៌ស និងកាបូបយួរដៃពណ៌ស សំរាប់ពេលព្រឹក ដល់ថ្ងៃត្រង់ ។

-ស្បែកជើងពណ៌ខ្មៅ និងកាបូបយួរដៃពណ៌ខ្មៅ សំរាប់ពេលល្ងាច ។

-រូបគំនូរឯកសណ្ឋានប្រពៃណីសំរាប់សមាជិក សមាជិកា រាជរដ្ឋាភិបាល និងអនុរដ្ឋលេខាធិការ មានដូចក្នុងឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យ នេះ ។

**មាត្រា ៥.-**

ការប្រើប្រាស់ឯកសណ្ឋានសំរាប់សមាជិក រាជរដ្ឋាភិបាល និងអនុរដ្ឋលេខាធិការ ត្រូវបានកំណត់ដូចខាងក្រោម :

-ឯកសណ្ឋានផ្លូវការ សំរាប់ប្រើប្រាស់ក្នុងឱកាសទិវាបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗទៀតរបស់រដ្ឋ ។

-ឯកសណ្ឋានប្រពៃណីជាតិ សំរាប់ប្រើប្រាស់ក្នុងឱកាសទិវាបុណ្យប្រពៃណីជាតិ និងសាសនាដែលប្រារព្ធឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម និងទីកន្លែងផ្សេងៗទៀត ។

ឯកសណ្ឋានទាំងពីរប្រភេទខាងលើនេះ ត្រូវស្លៀកពាក់ទៅតាមការកំណត់របស់គណកម្មការអចិន្ត្រៃយ៍ រៀបចំបុណ្យជាតិ-អន្តរជាតិ ។

**មាត្រា ៦.-**

មន្ត្រីដែលមានឋានៈស្មើ ឬប្រហាក់ប្រហែលមិនអាចប្រើប្រាស់សក្តិស្មា សក្តិកអាវ សក្តិចុងដៃអាវ ដែលមានចែងក្នុងព្រះរាជក្រឹត្យនេះឡើយ ។

**មាត្រា ៧.-**

ការចំណាយសំរាប់ផលិតសក្តិ ជាបន្ទុករបស់រាជរដ្ឋាភិបាល ។ ការចំណាយសំរាប់ឯកសណ្ឋានជាសំលៀកបំពាក់ ស្បែកជើង និងកាបូប ជាបន្ទុករបស់សាមីខ្លួនផ្ទាល់ ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.-**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

***

ឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០១/០៣១
ចុះថ្ងៃទី.០៥...ខែ.កុម្ភៈ....ឆ្នាំ.២០០១.....ស្តីពីសញ្ញាសក្តិ
និង ឯកសណ្ឋាន នៃសមាជិករាជរដ្ឋាភិបាល និងអនុរដ្ឋលេខាធិការ

## នាយករដ្ឋមន្ត្រី

សក្តិកអាវ



សក្តិស្មា



សក្តិដៃអាវ



ឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យលេខ.នស/រកត/០២០១/០៣១
ចុះថ្ងៃទី..០៥..ខែ.កុម្ភៈ...ឆ្នាំ.២០០១.....ស្ដីពីសញ្ញាសក្ដិ
និង ឯកសណ្ឋាន នៃសមាជិករាជរដ្ឋាភិបាល និងអនុរដ្ឋលេខាធិការ

## ឧបនាយករដ្ឋមន្ត្រី

សក្ដិកអាវ



សក្ដិស្មា



សក្ដិដៃអាវ



ឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០១/០៣១
ចុះថ្ងៃទី.០៥...ខែ.កុម្ភៈ...ឆ្នាំ.២០០១....ស្ដីពីសញ្ញាសក្ដិ
និង ឯកសណ្ឋាន នៃសមាជិករាជរដ្ឋាភិបាល និងមន្ត្រីលេខាធិការ

## ទេសរដ្ឋមន្ត្រី

សក្តិកអាវ



សក្តិស្មា



សក្តិដៃអាវ



ឧបសម្ព័ន្ធទី៤ នៃព្រះរាជក្រឹត្យលេខ.នស/រកត/០២០១/...
ចុះថ្ងៃទី.១៥...ខែ.កុម្ភៈ...ឆ្នាំ.២០០១....ស្តីពីសញ្ញាសក្តិ
និង ឯកសណ្ឋាន នៃសមាជិករាជរដ្ឋាភិបាល និងអនុរដ្ឋលេខាធិការ

រដ្ឋមន្ត្រី

សក្តិកអាវ



សក្តិស្មា



សក្តិដៃអាវ



ឧបសម្ព័ន្ធទី៥ នៃព្រះរាជក្រឹត្យលេខ.នស/រកត/០២០១/០៣១
ចុះថ្ងៃទី.១៥...ខែ.កុម្ភៈ...ឆ្នាំ.២០០១...ស្ដីពីសញ្ញាសក្តិ
និង ឯកសណ្ឋាន នៃសមាជិករាជរដ្ឋាភិបាល និងមន្ត្រីលេខាធិការ

## រដ្ឋលេខាធិការ

សក្តិកអាវ



សក្តិស្មា



សក្តិដៃអាវ



ឧបសម្ព័ន្ធទី៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០១/០៣១

ចុះថ្ងៃទី.០៥...ខែ.កុម្ភៈ....ឆ្នាំ.២០០១.....ស្តីពីសញ្ញាសក្តិ

និង ឯកសណ្ឋាន នៃសមាជិករាជរដ្ឋាភិបាល និងអនុរដ្ឋលេខាធិការ

## អនុរដ្ឋលេខាធិការ

សក្តិកអាវ



សក្តិស្មា



សក្តិដៃ





## ឯកសណ្ឋានផ្លូវការ

ឧបសម្ព័ន្ធទី៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០០១/០១១

ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីសញ្ញាសក្តិ

និង ឯកសណ្ឋាន នៃសមាជិករាជរដ្ឋាភិបាល និងអនុរដ្ឋលេខាធិការ



## ឯកសណ្ឋានប្រពៃណី

ឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០០១/០៣១
ចុះថ្ងៃទី..០៥...ខែ..កុម្ភៈ...ឆ្នាំ..២០០១....ស្តីពីសញ្ញាសក្តិ
និង ឯកសណ្ឋាន នៃ អគ្គាធិការ អគ្គាធិការរង និងអនុរដ្ឋលេខាធិការ